**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខធ៥...០២៥...១១៩ប្រ.ការ.សលា ថ្ងៃចន្ទ ១រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## កម្រៃសម្រាប់ការប្រើប្រាស់សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក របស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងអំពីកម្រៃសម្រាប់ការប្រើប្រាស់សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក (ប្រព័ន្ធ OBS) ដូចខាងក្រោម៖

**១. កម្រៃប្រចាំឆ្នាំ**

- ចំនួន ៤០០.០០០ រៀល (បួនរយពាន់រៀល) ហើយកម្រៃនេះនឹងត្រូវបានលើកលែងចំពោះក្រសួង-ស្ថាប័នរដ្ឋ។
- ធនាគារជាតិនៃកម្ពុជា នឹងកាត់កម្រៃប្រចាំឆ្នាំដោយស្វ័យប្រវត្តិពីគណនីចរន្តរបស់សមាជិក៖
    - នៅពេលទទួលបានការអនុញ្ញាតឱ្យចូលជាសមាជិកថ្មីនៃប្រព័ន្ធ OBS និង
    - នៅក្នុងខែមករា នៃឆ្នាំនីមួយៗ ចំពោះសមាជិកចាស់។

**២. កម្រៃ E-Token**

- ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុង ១គ្រឿង។ ចំពោះ ក្រសួង-ស្ថាប័នរដ្ឋនីមួយៗ នឹងទទួលបាន E-Token ចំនួន ២គ្រឿងដោយឥតគិតថ្លៃ នៅពេលស្នើសុំប្រើប្រាស់ប្រព័ន្ធ OBS ដំបូង។
- ធនាគារជាតិនៃកម្ពុជា នឹងកាត់កម្រៃ E-Token ដោយស្វ័យប្រវត្តិពីគណនីចរន្តរបស់សមាជិក តាមចំនួន Authorizer ជាក់ស្តែង៖
    - នៅពេលទទួលបានការអនុញ្ញាតឱ្យចូលជាសមាជិកថ្មីនៃប្រព័ន្ធ OBS និង
    - នៅពេលទទួលបានការអនុញ្ញាតឱ្យបន្ថែម Authorizer ចំពោះសមាជិកចាស់។

សេចក្តីជូនដំណឹង លេខធ៥-០១៩-១០៤៩ សជណ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង់កម្រៃពីការប្រើប្រាស់សេវា NBC Online Banking System (OBS) និងខ្លឹមសារទាំងឡាយណាដែលផ្ទុយពីស្មារតីនៃសេចក្តីជូនដំណឹងនេះ ត្រូវចាត់ទុកជានិរាករណ៍។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ត.ប. ទេសាភិបាល**
**អគ្គនាយកប្រតិបត្តិការ**

**គីមធី កោមលី**

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧